ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ២៣/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន
# ដឹកនាំដំណើរទស្សនកិច្ចអង្គទូតទៅកាន់ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំដំណើរទស្សនកិច្ចរបស់ប្រធាន និងតំណាងនៃស្ថានបេសកកម្មការទូត ព្រមទាំងទីភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ (អ.ស.ប) និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលធ្វើការងារផ្នែកសកម្មភាពមីនប្រចាំកម្ពុជា ចំនួន ៦០រូប ទៅកាន់ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ នៅថ្ងៃទី ២២-២៣ ខែសីហា ឆ្នាំ២០២៥។

គណៈប្រតិភូបានចុះទៅដល់មូលដ្ឋានភូមិជោគជ័យ និងភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលកម្លាំងយោធាថៃបានចូលមករាយបន្លាលួស និងដាក់រនាំង ដាក់កង់ឡាន មិនឱ្យប្រជាជនចូលទៅលំនៅដ្ឋានខ្លួនវិញបាន។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានពាំនាំនូវការសួរសុខទុក្ខ ការនឹករលឹកយ៉ាងជ្រាលជ្រៅ និងការចូលរួមរំលែកទុក្ខលំបាករបស់ប្រជាជន ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះប្រជាពលរដ្ឋទាំង១០គ្រួសារ ដែលរងផលប៉ះពាល់ដោយសកម្មភាពយោធាថៃ។

គណៈប្រតិភូបានបន្តដំណើរទៅពិនិត្យទីតាំងវត្តប្រាសាទតាមាន់សែនជ័យ ភូមិតាមាន់សែនជ័យ ឃុំគោកមន ដែលបានរងគ្រោះពីការទម្លាក់គ្រាប់បែក និងទីតាំងទម្លាក់គ្រាប់ MK84 នៅភូមិប្ញជួន ឃុំគោកមន ស្រុកបន្ទាយអំពិល នៅខេត្តឧត្តរមានជ័យ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានបញ្ជាក់នូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីជានានូវបទឈប់បាញ់ឱ្យបានពេញលេញប្រកបដោយប្រសិទ្ធភាព ដើម្បីអនុញ្ញាតឱ្យប្រជាជនដែលរងផលប៉ះពាល់ទាំងអស់ អាចវិលត្រលប់ទៅលំនៅដ្ឋានវិញដោយសុវត្ថិភាពក្នុងពេលឆាប់ៗ។

គណៈប្រតិភូអង្គទូតបានសម្តែងនូវក្តីសង្ឃឹមថា សន្តិភាពពេញលេញនឹងត្រូវបានស្តារឡើងវិញឆាប់ៗ ហើយបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការគោរព និងការអនុវត្តកិច្ចព្រមព្រៀងបទឈប់បាញ់អោយបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដើម្បីឈានទៅសម្រេចដំណោះស្រាយដោយសន្តិវិធីយូរអង្វែង និងអនុញ្ញាតឱ្យប្រជាជនភៀសសឹកអាចវិលត្រឡប់ទៅលំនៅដ្ឋានវិញ និងបន្តជីវភាពរស់នៅប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ៕

ថ្ងៃសៅរ៍ ១៥រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០២៥

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

Nº. PR 23 /2025 MFA.IC

PRESS RELEASE

**His Excellency Deputy Prime Minister PRAK Sokhonn led a diplomatic visit to Banteay Meanchey and Oddar Meanchey provinces.**

On 22–23 August 2025, His Excellency Deputy Prime Minister PRAK Sokhonn, Minister of Foreign Affairs and International Cooperation, led a diplomatic visit comprising of Ambassadors, Representatives of Foreign Missions, Specialize agencies of the United Nations ( UN ), international organizations, and foreign non-governmental organizations specialized on land mine in Cambodia, totaling 60 participants to Banteay Meanchey and Oddar Meanchey provinces.

The delegation visited areas where barbed wire, black shade nets, barricades, and tires had been laid by Thai military in Chouk Chey and Prey Chan villages, O Bei Choan commune, O Chrov district, Banteay Meanchey province, which are prohibiting local residents from returning to their homes.

His Excellency Deputy Prime Minister conveyed the heartfelt compassion and deepest sympathy of Samdech Akka Moha Sena Padei Techo HUN Sen, President of the Senate, and Samdech Moha Bovor Thipadei HUN Manet, Prime Minister of the Kingdom of Cambodia, to the families affected by Thai military action.

The delegation continued to inspect the bomb site at Wat Prasat Tamone Sen Chey in Tamone Sen Chey village, Kouk Mon commune, and the MK-84 bomb site in Thmor Doun village, Kouk Mon commune, Banteay Ampil district, Oddar Meanchey province.

His Excellency Deputy Prime Minister stated that the Royal Government's strong commitment to alleviating the hardships of the affected families and ensuring their safe return to their homes at the earliest possible time, by making every effort to achieve a full and effective ceasefire.

The delegation expressed its expectation that the complete full peace will be restored in the near future and empathized the complete and effective cease fire will be implemented in order to reach the enduring peace and permit the displaced Cambodian people affected by the armed conflict and underscored the importance of fully respecting and implementing the ceasefire agreement as a crucial step towards a peaceful and lasting solution. The delegation further expressed hope that full peace would soon be restored and people be able to return to their homes and resume their lives in safety and dignity.

Phnom Penh, 23 August 2025


ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
Ministry of Foreign Affairs
and International Cooperation


ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
Ministry of Foreign Affairs
and International Cooperation